**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃកិច្ចប្រជុំរបស់មេដឹកនាំអាស៊ាន
## នៅថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០២១ ទីក្រុងហ្សាការតា

តបតាមការអញ្ជើញរបស់ព្រះចៅស៊ុលតង់ **ហាជី ហាសសាណាល់ បុលគីយ៉ាស់ មុយអ៊ីហ្សាឌីន វ៉ាឌូឡាហ៍** (Sultan Haji Hassanal Bolkiah Mu'Izzaddin Waddaulah) នៃប្រទេសព្រុយណេដារ៉ូសាឡឹម ជាប្រធានអាស៊ាននាពេលបច្ចុប្បន្ន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ អញ្ជើញទៅចូលរួមកិច្ចប្រជុំរបស់មេដឹកនាំអាស៊ាន ដែលបានរៀបចំនៅលេខាធិការដ្ឋានអាស៊ាន នាទីក្រុងហ្សាការតា សាធារណរដ្ឋឥណ្ឌូនេស៊ី នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២១។ នេះគឺជាកិច្ចប្រជុំកំពូលលើកទី១ក្នុងទម្រង់ជាការចូលរួមដោយផ្ទាល់ ចាប់តាំងពីជំងឺរាតត្បាតកូវីដ-១៩ បានផ្ទុះឡើងកាលពីដើមឆ្នាំ២០២០។

មេដឹកនាំអាស៊ានបានពិនិត្យមើលវឌ្ឍនភាពនៃការកសាងសហគមន៍អាស៊ាន ដែលកំពុងបន្តដំណើរការទៅមុខ និងពិភាក្សាអំពីការងារឆ្ពោះទៅរៀបចំចក្ខុវិស័យសហគមន៍អាស៊ានក្រោយឆ្នាំ២០២៥ និងគំនិតផ្តួចផ្តើមនានា ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងរួមរបស់អាស៊ាន ដើម្បីឆ្លើយតប និងស្តារឡើងវិញពីផលប៉ះពាល់នៃជំងឺរាតត្បាតកូវីដ-១៩។ ស្តីពីទំនាក់ទំនងខាងក្រៅតំបន់ មេដឹកនាំអាស៊ានបានលើកអំពីសារៈសំខាន់ក្នុងការបន្តពង្រឹង និងពង្រីកភាពជាដៃគូរវាងអាស៊ាន និងដៃគូខាងក្រៅគ្រប់លំដាប់ថ្នាក់ ហើយក៏បានគូសបញ្ជាក់ពីសារៈសំខាន់នៃការឯកភាព និងមជ្ឈភាពរបស់អាស៊ាន ដើម្បីប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាប្រឈមរួមគ្នា និងថែរក្សាសន្តិភាព ស្ថិរភាព និងសន្តិសុខនៅក្នុងតំបន់ ។

មេដឹកនាំអាស៊ានបានពិភាក្សាគ្នាយ៉ាងទូលំទូលាយលើបញ្ហាតំបន់ និងអន្តរជាតិ ដែលជាក្តីបារម្ភរួម ជាពិសេសការវិវត្តថ្មីៗនៅក្នុងប្រទេសមីយ៉ាន់ម៉ា។ មេដឹកនាំអាស៊ានបានសម្រេច**ការឯកភាពគ្នាជាឯកច្ឆន្ទលើប្រាំចំណុចស្តីពីជំហានចាំបាច់** ដើម្បីបន្ធូរបន្ថយភាពតានតឹង បង្កលក្ខណៈសម្រាប់កិច្ចសន្ទនា និងបោះជំហានទៅមុខជាបន្តបន្ទាប់ទៅរកសំណោះស្រាយដោយសន្តិវិធី ដែលរួមមាន (១)ការបញ្ឈប់រាល់អំពើហឹង្សា (២)កិច្ចសន្ទនាប្រកបដោយស្ថាបនារវាងភាគីពាក់ព័ន្ធដើម្បីផលប្រយោជន៍ប្រជាជន (៣)ការចាត់តាំងប្រេសិតពិសេសរបស់អាស៊ានដើម្បីសម្របសម្រួលដំណើរការកិច្ចសន្ទនា (៤)ផ្តល់ជំនួយមនុស្សធម៌តាមរយៈមជ្ឈមណ្ឌលអាស៊ានដើម្បីសម្របសម្រួលជំនួយមនុស្សធម៌ និងគ្រប់គ្រងគ្រោះមហន្តរាយ និង (៥)ទស្សនកិច្ចរបស់ប្រេសិតពិសេសនៅមីយ៉ាន់ម៉ាដើម្បីជួបជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

**សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចែករំលែកអំពីបទពិសោធន៍ជោគជ័យរបស់កម្ពុជាក្នុងការអនុវត្តនយោបាយឈ្នះ-ឈ្នះ ដើម្បីនាំមកនូវសន្តិភាព និងការផ្សះផ្សាជាតិបិតបញ្ចប់សង្គ្រាមរ៉ាំរ៉ៃ និងបានស្នើឡើងនូវជំហានជាក់ស្តែងមួយចំនួន ពោលគឺ (១)ការបញ្ឈប់អំពើហិង្សា និងការប្រកាន់ភាពអត់ធ្មត់បំផុតដោយគ្រប់ភាគីពាក់ព័ន្ធ (២)ការទទួលតួនាទីអាស៊ាន និងការបញ្ជូនប្រេសិតពិសេសទៅមីយ៉ាន់ម៉ា ដើម្បីជួយអន្តរាគមន៍សម្របសម្រួល និង(៣)ការអនុញ្ញាតឲ្យមានការផ្តល់ជំនួយមនុស្សធម៌ពីអាស៊ាន ដែលបានរួមចំណែកដល់**ការឯកភាពគ្នាជាឯកច្ឆន្ទលើប្រាំចំណុច**។ សម្តេចតេជោក៏បានសង្កត់ធ្ងន់លើសារៈសំខាន់នៃការកសាងទំនុកចិត្ត និងការប្តេជ្ញាកំរិតនយោបាយពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងការធ្វើសម្បទានដើម្បីសម្រុះសម្រួលការព្រួយបារម្ភរបស់ផងគ្នា និងការផ្តោតគោលបំណងធំបំផុតទៅលើការបញ្ឈប់បង្ហូរឈាមគ្នា សន្តិភាព និងភាពសុខដុមចីរកាល។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានមានប្រសាសន៍ផងដែរអំពីការចាំបាច់ត្រូវពង្រឹងបន្ថែមទៀតនូវកិច្ចខិតខំប្រឹងប្រែងរបស់អាស៊ាន ដើម្បីសម្រេចគោលដៅកសាងសហគមន៍អាស៊ាន បើទោះបីមានការរាំងស្ទះដោយសារជំងឺកូវីដ-១៩ ក៏ដោយ។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់អំពីសារៈសំខាន់នៃភាពជាដៃគូរវាងអាស៊ាន និងដៃគូខាងក្រៅ ព្រមទាំងគាំទ្រដល់ការពង្រឹង និងពង្រីកទំនាក់ទំនងជាមួយដៃគូសន្ទនារបស់អាស៊ាន។

ដោយឡែក ក្នុងឱកាសកិច្ចប្រជុំកំពូលអាស៊ាននេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ហ៊ុន សែន បានឆ្លៀតឱកាសជួបជាមួយ **ឯកឧត្តម ចូកូ វីដូដូ** ប្រធានាធិបតីនៃសាធារណរដ្ឋឥណ្ឌូណេស៊ី ដើម្បីផ្លាស់ប្តូរយោបល់អំពីការលើកកម្ពស់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគី រវាងប្រទេសកម្ពុជា និងឥណ្ឌូនេស៊ី។ ថ្នាក់ដឹកនាំទាំងពីរបានសម្តែងការពេញចិត្តចំពោះការរីកចំរើននៃទំនាក់ទំនងទ្វេភាគី និងសហប្រតិបត្តិការប្រកបដោយផ្លែផ្ការវាងប្រទេសទាំងពីរ ហើយបានប្តេជ្ញាខិតខំទ្វេដង ដើម្បីរឹតចំណងទាក់ទងទ្វេភាគី និងពង្រីកកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ។ ថ្នាក់ដឹកនាំទាំងពីរបានថ្លែងអំណរគុណដល់គ្នាទៅវិញទៅមក ចំពោះការចាក់វ៉ាក់សាំងជូនដល់មន្ត្រីការទូត និងប្រជាជនឥណ្ឌូនេស៊ីនៅកម្ពុជា ក៏ដូចជាមន្ត្រីការទូត និងប្រជាជនកម្ពុជានៅឥណ្ឌូនេស៊ី ហើយបានយល់ស្របអំពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការជិតស្និទ្ធដើម្បីយកឈ្នះលើវិបត្តិសុខភាពដែលមិនធ្លាប់មានពីមុនមក និងពង្រឹងភាពរឹងមាំ។

ក្នុងថ្ងៃដដែលនោះដែរ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក៏មានជំនួបជាមួយ **ឯកឧត្តម ផាម មិញជិញ** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី និងផ្លាស់ប្តូរយោបល់លើបញ្ហាតំបន់និងអន្តរជាតិដែលមានការចាប់អារម្មណ៍និងកង្វល់រួម។ នាយករដ្ឋមន្ត្រីទាំងពីរបានសម្តែងការពេញចិត្តដូចគ្នាចំពោះវឌ្ឍនភាពនៃទំនាក់ទំនងកម្ពុជា - វៀតណាម ដែលមិនចេះរីងស្ងួត ដោយឈរលើគោលការណ៍នៃការជឿទុកចិត្តគ្នាទៅវិញទៅមក ភាពជាអ្នកជិតខាងល្អ សាមគ្គីភាព សន្តិភាព និងស្ថិរភាព។ នាយករដ្ឋមន្ត្រីទាំងពីរបានបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្ត ក្នុងការបន្ត កិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធនៅលើឆាកអន្តរជាតិ ដើម្បីផលប្រយោជន៍ទៅវិញទៅមកនៃប្រទេសទាំងពីរ និងឆ្ពោះទៅរកការជំរុញសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងតំបន់ និងទៅអនាគត។

**សម្តេចតេជោនាយករដ្ឋមន្ត្រី**បានថ្លែងអំណរគុណឥណ្ឌូនេស៊ី និងវៀតណាម ចំពោះការគាំទ្រកម្ពុជារៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី ១៣ ក្នុងឆ្នាំ២០២១នេះ និងប្រធានអាស៊ានក្នុងឆ្នាំ២០២២៕

ថ្ងៃសៅរ៍ ១៣កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០២១